**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២៣១ប្រ
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤
**<u>សាលដីកា</u>**
លេខ:២៦៤
ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ............ ជាចៅក្រម
៤-លោក ........... ជាចៅក្រម
៥-លោក ............. ជាចៅក្រមរបាយការណ៍

**<u>ក្រឡាបញ្ជី</u>**
-លោក .............

**<u>តំណាងមហាអយ្យការ</u>**
-ឯកឧត្តម ............ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ១៦(ជ) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៦៦ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះគចថ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅផ្ទះលេខ១៣(ឈ) ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ទណ្ឌឫស្សីកែវក្រុង ភ្នំពេញ ។

ចុងចម្លើយឈ្មោះសស (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៥ឆ្នាំ ជាតិខ្មែរទីលំនៅផ្ទះលេខ១២៤(ឈ) ក្រុម៣ ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

ផ្ទេរសិទ្ធិឱ្យឈ្មោះសៅ សេន ។

មានមេធាវីលោកលអេងរតនៈ។

**<u>កម្មវត្ថុបណ្តឹង:</u>**ប្តឹងសុំកិច្ចប្រញាប់

បានឃើញបណ្តឹងសាទុក្ខលេខ១៨៤ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះសៅ សេន ទទួលសិទ្ធិពីចុងចម្លើយឈ្មោះសស ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ១៦(ជ)ចុះថ្ងៃទី២០ខែឧសភាឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២៣១ប្រ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងទាស់ចុះថ្ងៃទី១៩-០១-២០០៤ របស់អ្នកស្រីគឹម ចាន់ថូ បញ្ជាក់ថា តុលាការបានចេញដីកាហាមឃាត់ផ្ទះរបស់ខ្លួននោះ ពុំត្រឹមត្រូវទេ ព្រោះផ្ទះខ្លួន និងលុយដែលឈ្មោះសៅ សេន ទាមទារនោះពុំពាក់ព័ន្ធជាមួយឈ្មោះសៅ សេន ទាំងអស់ទេ ។ ហើយការហាមឃាត់របស់តុលាការនេះ ជាហេតុធ្វើឱ្យខូចប្រយោជន៍ដល់ខ្លួន ។

បានឃើញដីកាសម្រេចតាមពាក្យសុំលេខ០១(ដ) ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៥-០១-២០០៤ របស់ឈ្មោះសស ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ហាមឃាត់ឈ្មោះគឹម ចាន់ថូ មិនឱ្យលក់ដូរ បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយ ដល់អ្នកដទៃនូវផ្ទះលេខ១៣ឈ ស្ថិតនៅក្រុមទី០១ ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

៣-បង្គាប់ឱ្យឈ្មោះសស បង់ប្រាក់ប្រដាប់ក្តី គឺពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ បូករួម ២០០០រៀល ។

៤-សេចក្តីសម្រេចនេះ មានអានុភាពអនុវត្តភ្លាមៗ ។

៥-បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលដំណឹងពីដីកាសម្រេចនេះ ។

បានឃើញបណ្តឹងទាស់ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះភីម ចាន់ថូ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចលេខ០១(ដ)ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ០៣(ដ)ចុះថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ដែលមានអ្វីមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី១៩-០១-២០០៤ របស់អ្នកស្រីគឹម ចាន់ថូ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សេចក្តីសម្រេចលេខ០១(ដ) ចុះថ្ងៃទី១២-០១-២០០៤ ទុកជាបានការ ពេញទាំងមូល ។

៣-បង្គាប់ឱ្យអ្នកស្រីគឹម ចាន់ថូ បង់ប្រាក់ប្រដាប់ក្តីចំនួន៤.០០០រៀល ។

៤-ដីកាសម្រេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។ គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៤ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៣(ដ) ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៦(ដ) ចុះថ្ងៃទី២០ ខែឧសភា ឆាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-០២-២០០៤ របស់ឈ្មោះគឹម ចាន់ថូ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បដិសេធដីកាសម្រេចកិច្ចការប្រញាប់លេខ០៣(ដ) ចុះថ្ងៃទី២៦-០១-២០០៤ របស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣-ទទួលពាក្យសុំដីកាសម្រេចតាមពាក្យសុំ ចុះថ្ងៃទី០៤-០១-២០០៤ របស់ឈ្មោះសស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍គឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្ដី ២៥៥០៛ វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ១០០០០៛ សរុប១៣០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ។ ចំពោះមុខគូក្ដី មេធាវី ការពារគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ១៨៤ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះសៅ សេន ទទួលសិទ្ធិពីចុងចម្លើយឈ្មោះសស ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៦(ជ) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

បានឃើញសារណាការពារចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះសៅ សេន ។

បានឃើញសារណាតប ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៤ របស់ឈ្មោះគឹម ចាន់ថូ ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ សាលដីកាលេខ១៦(ជ) ចុះថ្ងៃទី២០-០៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។សូមក្រុមប្រឹក្សាជំនុំជំរះសម្រេច ។

បានស្ដាប់ចម្លើយរបស់ឈ្មោះសៅ សេន នាពេលសវនាការថា ៖ បានជាខ្លួនប្ដឹងសាទុក្ខពីសាលដីការបស់សាលាឧទ្ធរណ៍ មកពីសាលាឧទ្ធរណ៍កាត់សេចក្ដីមិនត្រឹមត្រូវ ព្រោះផ្ទះនេះជាផ្ទះ របស់អ្នកស្រីគចថ ខ្លួននៅតែសុំឃាត់ផ្ទះនេះដដែល ។

បានស្ដាប់ចម្លើយរបស់ឈ្មោះគឹម ចាន់ថូ នាពេលសវនាការថាៈ ផ្ទះនេះជាផ្ទះបងស្រីខ្លួន សព្វថ្ងៃខ្លួនស្នាក់នៅជាមួយបង ផ្ទះខ្លួនលេខ២០ មិនមែនលេខ១៣ទេ ។ សូមលោកប្រធាន ជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកលអេងរតនៈជាមេធាវីការពារឱ្យចុងចម្លើយ បានលើកឡើងថា បងប្រុសកូនក្ដីខ្លួនត្រូវបានគេសម្លាប់ ដូច្នេះគាត់សុំទាមទារសំណង ក្នុងពេលដែលគាត់ចំណាយក្នុងការចាប់ឃាតករ ។ ផ្ទះអ្នកស្រីគឹម ស៊ីណា ប្ដីឈ្មោះអោក សំអុល មិនមែនផ្ទះលេខ១៣(ឈ)ទេ គឺផ្ទះលេខ២០ឈ) ។ លិខិតបញ្ជាក់របស់មេភូមិបូរី១០០ខ្នង ចុះថ្ងៃទី១៥-៧-២០០៤ បានបញ្ជាក់ថា៖ ផ្ទះលេខ១៣(ឈ) ផ្លូវលំក្រុមទី១ ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ពិតជាផ្ទះរបស់ឈ្មោះគឹម ចាន់ថូ ប្រាកដមែន ។ នៅតុលាការក្រុងភ្នំពេញ គាត់ឆ្លើយថាផ្ទះលេខ១៣ (ឈ) ជាផ្ទះរបស់គាត់ដែរ ។ សំណូមពរ សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោល ។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយគូភាគី និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ :

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៨៤ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះសៅ សេន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍បដិសេធ ដីកាសម្រេចកិច្ចការប្រញាប់លេខ០៣(ជ) ចុះថ្ងៃទី២៦-១២-២០០៤ របស់តុលាការក្រុងភ្នំពេញ ដោយសំអាងហេតុថា លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី៣១-០៥-១៩៩៩ កិច្ចសន្យាចុះថ្ងៃទី៣១-០៥-១៩៩៩ កំណត់ហេតុចុះពិនិត្យដីធ្លី ចុះថ្ងៃទី៣១-៥-១៩៩៩ ថាផ្ទះលេខ ១៣(ឈ) ក្រុមទី១ ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលគចថ កំពុងស្នាក់នៅសព្វថ្ងៃពុំមែនជាផ្ទះរបស់ឈ្មោះសេ ឈាន ប្រពន្ធឈ្មោះគឹម ចាន់ថូ នោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថាៈ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចុះថ្ងៃទី៣១-០៥-១៩៩៩ កិច្ចសន្យាចុះថ្ងៃទី៣១៥-១៩៩៩ និងកំណត់ហេតុចុះពិនិត្យដីធ្លី ចុះថ្ងៃទី៣១-៥-១៩៩៩ ពុំមានខ្លឹមសារណាដែលនិយាយ ថា ផ្ទះលេខ១៣(ឈ) ស្ថិតក្នុងក្រុមទី១ ភូមិបូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវជាផ្ទះរបស់បងអ្នកស្រីគឹម ចាន់ថូ ដូចឯកសារដែលជូនមកជាភស្តុតាងទេ ។ ដូច្នេះ តុលាការកំពូល គប្បីហាមឃាត់អ្នកស្រីគឹម ចាន់ថូ មិនឱ្យលក់ដូរ-បញ្ចាំ ផ្ទេរសិទ្ធិ ឬធ្វើអំណោយដល់អ្នកដទៃនូវ ផ្ទះនេះ ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់អង្គសេចក្តី ។

-យល់ឃើញថា សាលដីកាលេខ១៦(ជ) ចុះថ្ងៃទី២០-៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះ មានការខុសឆ្គងទាំងទម្រង់និងគតិច្បាប់ ។

## ហេតុច្នេះ

## ១និច្ឆ័យសេចក្តចំពោះមុខគូក្ត

១-ទទួលបណ្តឹងសាទុក្ខលេខ១៨៤ ចុះថ្ងៃទី២៤ខែឧសភា ឆ្នាំ២០០៤ របស់អ្នកស្រីសៅ សេន ទុកជាត្រឹមត្រូវ ទាំងទម្រង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១៦(ជ) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ទាំងមូល ដោយឥតបង្វិល ។

៣-សម្រេចហាមឃាត់មិនឱ្យអ្នកស្រីគចថលក់ដូរបញ្ចាំផ្ទេរសិទ្ធិឬធ្វើអំណោយនូវផ្ទះទំនាស់លេខ១៣(ឈ) នៅ ក្រុមទី១ ភូមិប៉ូរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តីជាស្ថាពរ ។

៤-បញ្ជូនសំណុំរឿងកិច្ចការប្រញាប់លេខ២៣១ប្រ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៤ របស់តុលាការកំពូល ទៅ តុលាការក្រុងភ្នំពេញ ដើម្បីបញ្ជូនក្នុងរឿងអង្គសេចក្តី ។
របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី ។

៥-រឹបអូសប្រាក់ប្រដាប់ក្តី ដែលអ្នកស្រីសៅ សេន បានបង់នៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥០០០៛ សរុប១៩០០០៛ ហើយតម្រូវឱ្យអ្នកស្រីគឹម ចាន់ថូ សង ប្រាក់ចំនួន ១៩.០០០៛ នេះ ទៅអ្នកស្រីសៅ សេន វិញ ។

៦-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ។